HLB ConnectFirst

Hong Leong Bank

## ការតភ្ជាប់គណនីសម្រាប់សេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង

LINKING OF ACCOUNTS FOR HONG LEONG BUSINESS INTERNET/ ELECTRONIC BANKING

*(សេចក្តីសម្រេចត្រូវបានអនុម័តមុនដាក់ពាក្យស្នើសុំ និង/ឬពេលបើកគណនីចរន្ត)*

*(Where resolution passed before the application and/or opening of Current Account)*

# សម្រង់បញ្ជាក់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល

# CERTIFIED EXTRACT OF DIRECTORS RESOLUTION

ក្រុមប្រឹក្សាភិបាលនៃ________________________________________[“ក្រុមហ៊ុន”] បានអនុម័តសេចក្តីសម្រេចដូចខាងក្រោមនៅ ________________[កាលបរិច្ឆេទ] ៖

The Board of Directors of [“The Company”] passed the following resolution on [date]

**ដោយហេតុថា៖**

WHEREAS

1. ________________________________________(“ក្រុមហ៊ុនហូលឌីង (Holding Company)”) បានចុះ ឬ នឹងចុះកិច្ចព្រមព្រៀងលើសេវា និង/ឬផលិតផលដែលហៅថា សេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង និងសេវាផ្សេងទៀតដែលអាចត្រូវបានបន្ថែម ដកចេញ កែប្រែ ឬ ជំនួស (ជារួមហៅថា “សេវា”) ដោយធនាគារហុង លីអុង (ខេមបូឌា) ភីអិលស៊ី (តទៅនេះហៅថា “ធនាគារ ហុង លីអុង”) ឬ សន្តតិជនដោយសិទ្ធិ និងដោយចាត់តាំងរបស់ធនាគារហុង លីអុង នៅគ្រប់ពេល ឬពីពេលមួយទៅពេលមួយ ដើម្បីឱ្យក្រុមហ៊ុនហូលឌីងអាចបំពេញសេវាធនាគារបានតាមរយៈប្រព័ន្ធអ៊ីនធឺណិត ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌស្តីពីសេវា ដែលអាចរកបាននៅក្នុងគេហទំព័ររបស់ធនាគារហុង លីអុង (www.hlb.com.kh) (“បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់សេវាធនាគារតាមអ៊ីនធឺណិតសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារ ហុង លីអុង”) និងបញ្ញត្តិ និងលក្ខខណ្ឌ បន្ថែម កែប្រែ ឬ ជំនួសផ្សេងទៀតដែល ធនាគារ ហុង លីអុង បង្កើតឡើងពីពេលមួយទៅពេលមួយ។

   (“the Holding Company”) has entered or will enter into an agreement for the services and/or facilities described as Hong Leong business internet/ electronic banking and such other services as may be added, withdrawn, varied or replaced (collectively, “the Services”) by Hong Leong Bank (Cambodia) Plc (“HLBCAM”) or it successors in title and assigns at any time or from time to time which enables the Holding Company to perform banking services through the internet upon the terms and conditions of the Services, which are made available via HLBCAM’s website at www.hlb.com.kh (“the TERMS AND CONDITIONS FOR HONG LEONG BUSINESS INTERNET BANKING”) and such other additional, varied or substituted terms and conditions as HLBCAM may stipulate from time to time.”

2. ក្រុមហ៊ុនបើកគណនីដូចមានកំណត់ក្នុងឧបសម្ព័ន្ធ ១.០ ជាមួយ ធនាគារ ហុង លីអុង (“គណនីអាជីវកម្ម”) ដែលការបង្ហាញនេះត្រូវរួមបញ្ចូលទាំងគណនីដទៃទៀតដែលអាចត្រូវបានបើកដោយ ________________________ (“ក្រុមហ៊ុន”) ជាមួយ ធនាគារ ហុង លីអុង ពីពេលមួយទៅពេលមួយ។

3. The Company maintains the Account(s) as listed in Appendix 1.0 with HLBCAM (“the Business Accounts”) which expression shall include such other accounts which may be maintained by (“The Company”) with HLBCAM from time to time.

A. **ក្រុមប្រឹក្សាភិបាលបានសម្រេចដូចតទៅ៖**

   **It is hereby resolved as follow**

1. “គណនីអាជីវកម្មដែលបានបើកជាមួយ ធនាគារ ហុង លីអុង និងដូចបានរៀបរាប់ខាងក្រោម ត្រូវបានអនុញ្ញាតឱ្យក្រុមហ៊ុនហូលឌីងអាចចូលប្រើប្រាស់សេវាដែលបានផ្តល់ឱ្យដោយ ធនាគារ ហុង លីអុង ទៅកាន់ក្រុមហ៊ុនហូលឌីង បានចាប់ពីពេលនេះ និងពីពេលមួយទៅពេលមួយ។”

"THAT the Business Accounts maintained with HLBCAM and set forth below shall now and from time to time be made available for access by the Holding Company in relation to the Services provided by HLBCAM to the Holding Company";

2. "អនុញ្ញាតឱ្យបុគ្គលដែលទទួលសិទ្ធិពីសហគ្រាសអាជីវកម្ម ចូលប្រើប្រាស់សេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង សម្រាប់ និងក្នុងនាមរបស់ក្រុមហ៊ុនហូលឌីងពីពេលមួយទៅពេលមួយ ក្នុងការធ្វើប្រតិបត្តិការរាល់សេវាកម្មរបស់គណនីអាជីវកម្ម។"

"To allow the person(s) authorised by the Business to access Hong Leong business internet/ electronic banking for the Holding Business from time to time to transact under the Services for the Business Accounts."

3. "ក្រុមហ៊ុនយល់ព្រម និងអនុញ្ញាតឱ្យ ធនាគារ ហុង លីអុង ពឹងផ្អែកលើ និងធ្វើសកម្មភាពស្របតាមការបញ្ជាណែនាំ ឬការប្រាស្រ័យទាក់ទងនានា ("ការបញ្ជា") ដែលពីពេលមួយទៅពេលមួយ អាច ឬនឹងអាចធ្វើឡើងដោយ ឬក្នុងនាមក្រុមហ៊ុន និង/ឬក្រុមហ៊ុនហូលឌីង ចំពោះបុគ្គលដែលបានទទួលសិទ្ធិដើម្បីប្រើប្រាស់ និងអាចចូលប្រើប្រាស់សេវាតាមរយៈសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារហុង លីអុង ដោយមិនចាំបាច់មានការសួរនាំ ឬការបញ្ជាក់ពីភាគី ធនាគារ ហុង លីអុង ឡើយ ពាក់ព័ន្ធនឹងសិទ្ធិអំណាច ឬអត្តសញ្ញាណរបស់បុគ្គលដែលបានទទួលសិទ្ធិនោះ ឬ បុគ្គលផ្តល់ការបញ្ជា ឬនឹងអាចផ្តល់ការបញ្ជា ឬចំពោះភាពត្រឹមត្រូវតាមផ្លូវច្បាប់នៃការបញ្ជានោះផងដែរ។ ធនាគារ ហុង លីអុង មានសិទ្ធិចាត់ទុករាល់ការបញ្ជាទាំងនោះមានអានុភាពគតិយុត្តិលើក្រុមហ៊ុន និង/ឬក្រុមហ៊ុនហូលឌីង ហើយ ធនាគារ ហុង លីអុង ត្រូវមានសិទ្ធិធ្វើសកម្មភាពទាំងឡាយទាក់ទងនឹង ឬដោយផ្អែកលើការបញ្ជានោះ។ ក្នុងករណីនេះ ក្រុមហ៊ុន និង/ឬ ក្រុមហ៊ុនហូលឌីង យល់ព្រមទទួលខុសត្រូវនូវរាល់ហានិភ័យពាក់ព័ន្ធនឹងការបញ្ជានោះ ព្រមទាំងមិនតវ៉ានឹងសុពលភាព ភាពត្រឹមត្រូវតាមផ្លូវច្បាប់ និងភាពត្រឹមត្រូវនៃការបញ្ជានោះឡើយ។"

"THAT the Company agrees and authorises HLBCAM to rely upon and act in accordance with any instructions or communication ("Instructions") which may be from time to time be, or purport to be given by or on behalf of the Company and/or the Holding Company in respect of the persons authorised to use and to access the Services via Hong Leong business internet/ electronic banking without inquiry or verification on HLBCAM's part as to the authority or identity of the persons so authorised or the person giving or purporting to give the Instructions or as to the authenticity of such Instructions. HLBCAM is entitled to treat all such Instructions as binding upon the Company and/or the Holding Company and HLBCAM shall be entitled to take such steps in connection with or in reliance upon such Instructions. In this regard, the Company and/or the Holding Company agree to bear all risks involved in giving the Instructions and will not challenge the validity, authenticity and accuracy of the Instructions.

4. "លិខិតបញ្ជាក់សេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃសេចក្តីសម្រេចនេះត្រូវផ្តល់ទៅឱ្យ ធនាគារ ហុង លីអុង ហើយសេចក្តីសម្រេចនេះត្រូវមានសុពលភាពរហូតដល់ ធនាគារ ហុង លីអុង ទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ទុយពីនេះ ពីក្រុមហ៊ុន។"

"THAT a certified true copy of this resolution is to be furnished to HLBCAM and this resolution shall remain in force until notice in writing to the contrary is given to HLBCAM by the Company."

ក្រុមហ៊ុនយល់ព្រមដោយឥតលក្ខខណ្ឌ និងពុំអាចប្រកែកបានក្នុងការសងសំណងដល់ធនាគារ ហុង លីអុង និងបន្តសងសំណងដល់ធនាគារ ហុង លីអុង ចំពោះរាល់ពាក្យបណ្តឹង ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ការខូចខាត ថ្លៃចំណាយ និងការចំណាយនានាដែលអាចកើតមានឡើងចំពោះធនាគារ ហុង លីអុង ដែលកើតចេញពី ឬជាលទ្ធផលនៃសកម្មភាពដែលមានចែងក្នុងលិខិតនេះ។
The Company hereby unconditionally and irrevocably agree to indemnify the HLBCAM and shall keep HLBCAM indemnified against any and all actions, claims demands, liabilities, losses, damages, costs and expenses of whatever nature which the HLBCAM may suffer, incur or sustain arising from or as a result of hereof.

ការអនុញ្ញាតនេះត្រូវជំនួសឱ្យរាល់ការបញ្ជា ឬការអនុញ្ញាត ទោះដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលមានពីមុន ដែលចេញដោយក្រុមហ៊ុនពាក់ព័ន្ធនឹងសេវាធនាគារតាមអ៊ីនធឺណិត/អេឡិចត្រូនិកសម្រាប់អតិថិជនអាជីវកម្មរបស់ធនាគារ ហុង លីអុង។

This authorisation shall supersede any prior oral or written instruction or authorisation given by the Company in connection with the Hong Leong business internet/ electronic banking.

ធ្វើនៅថ្ងៃទី/ Dated this ______ ខែ/ day of _________ ឆ្នាំ២0/20_____

បានបញ្ជាក់ថាត្រឹមត្រូវ

Certified Correct,

| | |
|---|---|
| ឈ្មោះ: | ឈ្មោះ: |
| Name | Name |
| តំណែង*: | តំណែង*: |
| Designation* | Designation* |

* អភិបាល / លេខាក្រុមហ៊ុន

* Director / Company Secretary

ឧបសម្ព័ន្ធ ១.០
Appendix 1.0

| លេខគណនី<br>ACCOUNT NUMBER | ឈ្មោះគណនី<br>ACCOUNT NAME |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |